# របាយការណ៍វាយតម្លៃបឋមលើផលប៉ះពាល់

សំណើបញ្ញត្តិកម្ម: អនុក្រឹត្យស្តីពីការលើកទឹកចិត្ត ប្រតិបត្តិមេត្រីភាពបរិស្ថាន
ក្រសួង: ក្រសួងបរិស្ថាន

លេខយោង: ០០៦/បរស

កាលបរិច្ឆេទចាប់ផ្តើម: ថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១៨

កាលបរិច្ឆេទបញ្ចប់: ថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ២០១៨

## អត្ថាធិប្បាយសង្ខេបអំពីសំណើបញ្ញត្តិកម្ម

អនុក្រឹត្យនេះតម្រូវឲ្យនីតិបុគ្គល រូបវន្តបុគ្គល ដែលបានប្រតិបត្តិមេត្រីភាពបរិស្ថាន បានចូលរួមអនុវត្តបច្ចេកវិទ្យាទ្រទ្រង់បរិស្ថាន ការអភិវឌ្ឍដោយចីរភាព និងការចូលរួមទទួលខុសត្រូវក្នុងសង្គម។ អនុក្រឹត្យ នេះក៏តម្រូវឲ្យរៀបចំស្តង់ដាមេត្រីភាពបរិស្ថាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តស្តង់ដាមេត្រីភាពបរិស្ថាន កៀរគរធនធាន រៀបចំប្រភេទរង្វាន់លើកទឹកចិត្ត ផ្តល់រង្វាន់ និងសម្ភារៈលើកទឹកចិត្តនានាដល់នីតិបុគ្គល និងរូបវន្តបុគ្គលដែលប្រតិបត្តិតាមស្តង់ដាមេត្រីភាពបរិស្ថានបានល្អ ស្របតាមក្របខ័ណ្ឌគតិយុត្តពាក់ព័ន្ធ។
ដើម្បីទទួលបានការលើកទឹកចិត្ត និង ផ្តល់រង្វាន់មេត្រីភាពបរិស្ថាន ស្របតាមលក្ខខណ្ឌតម្រូវការផ្នែកបច្ចេកទេស មានការប្រើប្រាស់បច្ចេកវិទ្យាទ្រទ្រង់បរិស្ថាន សម្រាប់ផលិតកម្ម សេវាកម្ម និងការគ្រប់គ្រងសកម្មភាពអាជីវកម្ម លើកកម្ពស់កិច្ចគាំពារបរិស្ថាន ការអភិរក្សធនធានធម្មជាតិ ការការពារប្រព័ន្ធអេកូឡូស៊ី រួមមាន ធនធានទឹក ដី បរិយាកាស និងជីវៈចម្រុះដោយរក្សាបាននូវបរិស្ថានស្អាត កាត់បន្ថយឬលុបបំបាត់ការបំពុលបរិស្ថាន កាត់បន្ថយជាអតិបរមានូវផលប៉ះពាល់បរិស្ថាន ធនធានធម្មជាតិ លើកកម្ពស់ការថែរក្សាទំនៀមទម្លាប់ វប្បធម៌ ប្រពៃណី អត្តសញ្ញាណជាតិ និងអភិរក្សមរតកវប្បធម៌ផ្នែកចំណេះដឹងជាប្រពៃណី។

## ប្រភេទបញ្ញត្តិកម្ម

| ច្បាប់ | ព្រះរាជក្រឹត្យ | អនុក្រឹត្យ | ប្រកាស | សេចក្តីសម្រេច | សារាចរ | ផ្សេងទៀត |
|---|---|---|---|---|---|---|
| ☐ | ☐ | ☑ | ☐ | ☐ | ☐ | ☐ |

ផលប៉ះពាល់នៃសំណើបញ្ញត្តិកម្មលើវិស័យ៖

☐ សេដ្ឋកិច្ច ☐ សង្គមកិច្ច ☑ បរិស្ថាន ☐ ផ្សេងៗ

## ១. ការកំណត់បញ្ហា

### ១.ក. បញ្ហាចម្បងដែលបញ្ញត្តិកម្មមានបំណងដោះស្រាយ

**ការការពារ និងអភិរក្សបរិស្ថាននៅមានកម្រិត ៖** នីតិបុគ្គល និងរូបវន្តបុគ្គល មួយចំនួនដែលបានចូលរួមចំនែកការពារនិងអភិរក្សបរិស្ថាន ដើម្បីទទួលបានបរិយាកាសល្អ ជាគំរូក្នុងការអនុវត្ត និងទម្លាប់ល្អសម្រាប់អ្នកជំនាន់ក្រោយ ប៉ុន្តែការលើកទឹកចិត្តដល់អ្នកអនុវត្តមិនបានគ្រប់គ្នាទេ មានទៅតាមតំបន់ខ្លះក៏បាន តំបន់ខ្លះទៀតក៏មិនមាន។ ដូចនេះ ក្រសួងសម្រេចធ្វើអនុក្រឹត្យនេះដើម្បីឱ្យមានតម្លាភាព និងពង្រឹងឱ្យមានការចូលរួមចំនែកបន្ថែមទៀត។

- ឆ្នាំ២០១៧ បានផ្តល់ប័ណ្ណសរសើរមេត្រីភាពបរិស្ថាន និងលិខិតថ្លែងអំណរគុណដល់ជូនដល់និតីបុគ្គល និងរូបវន្តបុគ្គល សរុបចំនួន៦៧នាក់ ដែលបានចូលរួមប្រតិបត្តិល្អមេត្រីភាពបរិស្ថាន
- បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយចំនួនបីលើក ស្តីពីរង្វាន់លើកទឹកចិត្តមេត្រីភាពបរិស្ថាន លិខិតបទដ្ឋានគតិយុត្ត សូចនាករ លក្ខណៈវិច្ឆ័យ និងប្រភេទរង្វាន់មេត្រីភាពបរិស្ថាន នៅខេត្តកែប ខេត្តសៀមរាប និងរាជធានីភ្នំពេញ ដែលមានអ្នកចូលរួមចំនួន២៤០នាក់
- បានរៀបចំកម្មវិធីមេត្រីភាពបរិស្ថាន និងបានបញ្ជ្រាប ចំណេះដឹងដល់ប្រតិបត្តិករមេត្រីភាពបរិស្ថាន សាធារណៈជនគ្រប់វិស័យ ក្នុងការចូលរួមកិច្ចគាំពារបរិស្ថាន ការគ្រប់គ្រងធនធានធម្មជាតិ ការអភិរក្សជីវៈចម្រុះ និងការរស់នៅប្រកបដោយចីរភាព នៅខេត្តកែប និងខេត្តសៀមរាប។

**ការប្រកួតប្រជែង៖** ការផ្តល់រង្វាន់លើកទឹកចិត្តដល់អ្នកប្រតិបត្តិមេត្រីភាពបរិស្ថានបានល្អ ជាកត្តាជំរុញឱ្យផលិតកម្ម សេវាកម្ម និងការគ្រប់គ្រងសកម្មភាពអាជីវកម្មនានា មានការប្រកួតប្រជែងលើបរិស្ថានល្អ ដែលជាអត្ថប្រយោជន៍មួយដ៏ធំសម្រាប់សាធារណៈជន។

### ១.ខ. បញ្ហាពាក់ព័ន្ធផ្សេងទៀតដែលបញ្ញត្តិកម្មអាចជួយដោះស្រាយផង

**សុខភាពនិងសុវត្ថិភាពសាធារណៈ ៖** បរិស្ថានជារឿងដ៏សំខាន់ និងទទួលនូវការរិះគន់យ៉ាងខ្លាំងពីសំណាក់សាធារៈជនលើផលិតកម្ម សេវាកម្ម និងការគ្រប់គ្រងសកម្មភាពអាជីវកម្មនានា។ ផលិតកម្ម សេវាកម្ម និងការគ្រប់គ្រងសកម្មភាពអាជីវកម្មនានា អនុវត្តមិនស្របតាមស្តង់ដារទាំងស្រុងទេ ដូច្នេះហើយរាជរដ្ឋាភិបាលត្រូវធ្វើការលើកទឹកចិត្ត និងជំរុញដល់ពួកគេក្នុងការប្រតិបត្តិមេត្រីភាពបរិស្ថាន តាមរយៈការជូនជារង្វាន់ផ្សេងៗ ដើម្បីធ្វើឱ្យមានការប្រកួតប្រជែង លើអនាម័យ និងសុវត្ថិភាពដល់សាធារណៈជន។ វាជាផ្នែកមួយដ៏សំខាន់ជួយដល់ សុខភាព និងសុវត្ថិភាពសាធារណៈ។

### ១.គ. បញ្ជីលិខិតបទដ្ឋានគតិយុត្តមានស្រាប់ ដែលពាក់ព័ន្ធឬប្រហាក់ប្រហែល

| | |
|---|---|
| 1 | ច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ឆ្នាំ១៩៩៦ |
| 2 | ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ឆ្នាំ២០០៥ |

3 ច្បាប់ស្តីពីស្តង់ដាកម្ពុជា ឆ្នាំ២០០៧

4 ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ឆ្នាំ២០០៥

5 ច្បាប់ស្តីពីស្តង់ដាកម្ពុជា ឆ្នាំ២០០៧

6 អនុក្រឹត្យស្តីពីការបង្កើតមូលនិធិបរិស្ថាន និងសង្គម ឆ្នាំ២០១៦

ដោយសារច្បាប់អនុក្រឹត្យខាងលើមិនបានចែងពី យន្តការត្រួតពិនិត្យ វាយតម្លៃការប្រតិបត្តិមេត្រីភាពបរិស្ថាន និងរៀបចំប្រភេទរង្វាន់លើកទឹកចិត្ត ផ្តល់រង្វាន់ និងគ្រឿងលើកទឹកចិត្តនានាដល់នីតិបុគ្គល និងរូបវន្តបុគ្គល ដែលប្រតិបត្តិតាមស្តង់ដាមេត្រីភាពបរិស្ថានបានល្អ ស្របតាមក្របខ័ណ្ឌគតិយុត្តពាក់ព័ន្ធ។ ដូច្នេះហើយ អនុក្រឹត្យនេះ តម្រូវឲ្យនីតិបុគ្គល និងរូបវន្តបុគ្គល ចូលរួមដើម្បី លើកកម្ពស់កិច្ចគាំពារបរិស្ថាន ការអភិរក្សធនធានធម្មជាតិ ការការពារប្រព័ន្ធអេកូឡូស៊ី រួមមាន ធនធានទឹក ដី បរិយាកាស និងជីវៈចម្រុះដោយរក្សាបាននូវបរិស្ថានស្អាត កាត់បន្ថយឬលុបបំបាត់ការបំពុលបរិស្ថាន កាត់បន្ថយជាអតិបរមានូវផលប៉ះពាល់ចំពោះបរិស្ថាន និងធនធានធម្មជាតិ។

**១.ឃ. តើសំណើបញ្ញត្តិកម្មមានផលប៉ះពាល់អវិជ្ជមានដល់ការប្រកួតប្រជែងដែរឬទេ**

បញ្ញត្តិកម្មនេះពុំមានផលប៉ះពាល់អវិជ្ជមានដល់ការប្រកួតប្រជែងទេ។ ផ្ទុយទៅវិញ បែរជាជួយជំរុញលើកទឹកចិត្តដល់គូរប្រកួតប្រជែង សាធារណៈជន និងផ្តល់ប្រយោជន៍ដល់សង្គមផងដែរ។

## ២. គោលបំណង

វាយតម្លៃ និងផ្តល់រង្វាន់លើកទឹកចិត្តដល់នីតិបុគ្គល រូបវន្តបុគ្គលក្នុងការប្រតិបត្តិ មេត្រីភាពបរិស្ថានបានល្អស្របតាមក្របខ័ណ្ឌគតិយុត្តជាធរមាន ក្នុងព្រះរាជាណាចក្រកម្ពុជា។ វាយតម្លៃ លើកទឹកចិត្តដល់ការផលិត និងការប្រើប្រាស់ផលិតផលមេត្រីភាពបរិស្ថានមានប្រភពចេញពីផលិតកម្ម សេវាកម្ម និងការគ្រប់គ្រងសកម្មភាពអាជីវកម្មនានា ឆ្លើយតបទៅនឹងស្តង់ដា និងគោលការណ៍នៃកិច្ចគាំពារបរិស្ថាន ការអភិរក្សជីវៈចម្រុះ និងការគ្រប់គ្រងធនធានធម្មជាតិ ដោយនិរន្តរភាព សំដៅដល់ការរស់នៅប្រកបដោយចីរភាព លើកកម្ពស់ការយល់ដឹង និងជំរុញការចូលរួមរបស់សាធារណជនក្នុងសកម្មភាពមេត្រីភាពបរិស្ថាន និងការថែរក្សាអត្តសញ្ញាណកម្មជាតិ ស្របតាមក្របខ័ណ្ឌគតិយុត្តជាធរមានក្នុងព្រះរាជាណាចក្រកម្ពុជា។

- ជំរុញលើកទឹកចិត្ត ដល់នីតិបុគ្គល ឬ រូបវន្តបុគ្គលដែលប្រតិបត្តិមេត្រីភាពបរិស្ថាននៅក្នុងព្រះរាជាណាចក្រកម្ពុជា។

## ៣. ជម្រើស

ជម្រើសផ្សេងៗរួមទាំងសំណើបញ្ញត្តិកម្ម (សម្រាប់ការវិភាគលើផលប៉ះពាល់)

| |
|---|
| ១. អនុក្រឹត្យស្តីពី ការលើកទឹកចិត្ត ប្រតិបត្តិមេត្រីភាពបរិស្ថាន<br>២. រក្សាស្ថានភាពដើម (អប់រំ និងផ្សព្វផ្សាយពីប្រតិបត្តិមេត្រីភាពបរិស្ថាន) |

## ៤. ការប៉ាន់ស្មានបឋមលើប្រភេទបន្ទុកចំណាយភាគពួកកិច្ច និងផលចំណេញ

### ៤.១. ការកំណត់ភារកិច្ច និងប្រភេទបន្ទុកចំណាយ

| ជម្រើស | រាជរដ្ឋាភិបាល | ធុរកិច្ច |
|---|---|---|
| ជម្រើសទី១: អនុក្រឹត្យស្តីពី ការលើកទឹកចិត្ត ប្រតិបត្តិមេត្រីភាពបរិស្ថាន | - ចំណាយរៀបចំសេចក្តីព្រាងបញ្ញត្តិកម្ម<br>- ចំណាយរៀបចំផ្សព្វផ្សាយសិក្ខាសាលា<br>-បោះពុម្ពឯកសារផ្សព្វផ្សាយ<br>-ចំណាយលើការងាររដ្ឋបាល | - ចំណាយចូលរួមពិគ្រោះយោបល់<br>- សិក្ខាសាលាផ្សព្វផ្សាយបុគ្គលិក<br>- រៀបចំឯកសារព័ត៌មានពាក់ព័ន្ធ |
| ជម្រើសទី២: រក្សាស្ថានភាពដើម (អប់រំ និងផ្សព្វផ្សាយពីប្រតិបត្តិមេត្រីភាពបរិស្ថាន) | - បោះពុម្ពរូបភាពផ្សព្វផ្សាយ<br>- ការបណ្តុះបណ្តាលនីតិបុគ្គល រូបវន្តបុគ្គល | - ចូលរួមវគ្គបណ្តុះបណ្តាលរបស់ក្រសួងបរិស្ថាន<br>- ចំណាយក្នុងការអនុវត្តន៍តាមគោលការណ៍ណែនាំ(គោលការណ៍សុវត្ថិភាព) |

### ៤.២. ការកំណត់ប្រភេទនៃផលចំណេញ

| ជម្រើស | ប្រភេទនៃផលចំណេញ |
|---|---|
| ជម្រើសទី១: អនុក្រឹត្យស្តីពី ការលើកទឹកចិត្ត ប្រតិបត្តិមេត្រីភាពបរិស្ថាន | - មានការចូលរួមបន្ថែមក្នុងការប្រតិបត្តិមេត្រីភាពបរិស្ថាន<br>- បរិស្ថានស្អាត និងមានផាសុខភាព<br>- ការចូលរួមការការពារ និងអភិរក្សបរិស្ថានរឹតតែច្រើន<br>- អ្នកប្រតិបត្តិមេត្រីភាពបរិស្ថានល្អទទួលបានរង្វាន់<br>- ទាក់ទាញភ្ញៀវទេសចរ<br>- សាធារណៈជនមានការសប្បាយចិត្ត និងពេញចិត្ត |

| | |
|---|---|
| ជម្រើសទី២: រក្សាស្ថានភាពដើម (អប់រំ និងផ្សព្វផ្សាយពីប្រតិបត្តិមេត្រីភាពបរិស្ថាន) | - ចូលរួមក្នុងការប្រតិបត្តិមេត្រីភាពបរិស្ថាន<br>- មានការការពារ និងអភិរក្សបរិស្ថាន<br>- មានការទទួលបានការលើកទឹកចិត្ត |

## ៤.៣. វិសាលភាពនៃជម្រើសនីមួយៗ

| ជម្រើស | វិស័យ ឬប្រភេទធុរកិច្ច | ចំនួនធុរកិច្ច | ឯកសារយោង/ភស្តុតាង |
|---|---|---|---|
| ជម្រើសទី១: អនុក្រឹត្យស្តីពី ការលើកទឹកចិត្ត ប្រតិបត្តិមេត្រីភាពបរិស្ថាន | - អប់រំ យុវជន និងកីឡា<br>- ទេសចរណ៍ | ១០០ | |
| ជម្រើសទី២: រក្សាស្ថានភាពដើម (អប់រំ និងផ្សព្វផ្សាយពីប្រតិបត្តិមេត្រីភាពបរិស្ថាន) | - នីតិបុគ្គល រូបវន្តបុគ្គល | | |

## ៥. **កិច្ចពិគ្រោះយោបល់**

- ក្រុមការងារប្រតិបត្តិលិខិតបទដ្ឋានគតិយុត្ត(RIA) របស់ក្រសួងបរិស្ថានបានជួបប្រជុំជាមួយ នាយកដ្ឋានរង្វាន់ និងលើកទឹកចិត្ត ចំនួន០២លើក នៅក្រសួងបរិស្ថាន
- ក្រុមការងារប្រតិបត្តិលិខិតបទដ្ឋានគតិយុត្ត(RIA) និងក្រុមបច្ចេកទេសរបស់ក្រសួងបរិស្ថាន បានជួបប្រជុំពិភាក្សា និងពិគ្រោះយោបល់ជាមួយ ក្រុមប្រតិបត្តិលិខិតបទដ្ឋានគតិយុត្តរបស់ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ នៃទីស្តីការគណៈរដ្ឋមន្ត្រី និងមន្ត្រី មន្ទីរបរិស្ថានខេត្តសៀមរាប ចំនួន១លើក នៅមន្ទីរបរិស្ថានខេត្តសៀមរាប។

## ៦. **សន្និដ្ឋាន**

តើចាំបាច់ធ្វើ RIS ដែរឬទេ?

☐ចាំបាច់

☑មិនចាំបាច់

| |
|---|
| បើប្រៀបធៀបជម្រើសទាំងពីរ បានបង្ហាញថាៈ ជម្រើសទី១ មានផលចំណេញច្រើនជាងជម្រើសទី២ លើសពីនេះជម្រើសទីមួយបានជួយដល់បរិស្ថានក៏ដូចជាសង្គម និងបានបង្ហាញពីការយកចិត្តយ៉ាងខ្លាំងដល់ប្រជាជន របស់រាជរដ្ឋាភិបាល។ ដូច្នេះជម្រើសទី១គួរត្រូវបានជ្រើសរើស។ |

## ៧. ការអនុវត្តនិងការតាមដានត្រួតពិនិត្យ

ប្រសិនជាសំណើរៀបចំអនុក្រឹត្យថ្មីនេះ ត្រូវបានជ្រើសរើស វិធានការដើម្បីលើកកម្ពស់តម្លាភាព និងអភិបាលកិច្ចល្អក្នុងកំឡុងពេលប្រតិបត្តិ គឺត្រូវមានការផ្សព្វផ្សាយខ្លឹមសារអនុក្រឹត្យឱ្យបានទូលំទូលាយ ការវាយតម្លៃសកម្មភាពប្រតិបត្តិមេត្រីភាពបរិស្ថាន និងប្រភេទរង្វាន់លើកទឹកចិត្ត ត្រូវស្របតាមការកំណត់របស់អនុក្រឹត្យ។ លើសពីនេះអគ្គនាយកដ្ឋានចំណេះដឹង និងព័ត៌មានបរិស្ថាន នៃក្រសួងបរិស្ថាន ត្រូវមានយន្តការត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តស្តង់ដាមេត្រីភាពបរិស្ថាន កៀរគរធនធាន រៀបចំប្រភេទរង្វាន់លើកទឹកចិត្ត ផ្តល់រង្វាន់ និងសម្ភារៈលើកទឹកចិត្តនានាដល់នីតិបុគ្គល និងរូបវន្តបុគ្គល ដែលប្រតិបត្តិតាមស្តង់ដាមេត្រីភាពបរិស្ថានបានល្អ ស្របតាមក្របខ័ណ្ឌគតិយុត្តពាក់ព័ន្ធ។ ក្នុងករណីសំណើអនុក្រឹត្យថ្មីត្រូវបានជ្រើសរើស អនុក្រឹត្យថ្មីនេះគួរត្រូវបានពិនិត្យឡើងវិញរៀងរាល់០៥ឆ្នាំម្តង។

| ដំណើរការ | ឈ្មោះ | មុខងារ | ទំនាក់ទំនង |
|---|---|---|---|
| រៀបចំដោយ<br>ក្រសួងបរិស្ថាន | ឯកឧត្តម ចាយ សាមិត្ត | ប្រធានRIA | ០១២ ៩៩៨ ៧៨៩ |
| | លោក យិន សំរាយ | អនុប្រធានRIA | ០១១ ៨៧១ ៥៤១<br>yinsamray@gmail.com |
| | លោក រស់ ជ័រ | សមាជិក | ០១២ ៩៨៦ ០៩៨<br>roschor@gmail.com |
| | | | |
| | | | |
| | | | |
| ផ្តល់យោបល់ដោយ<br>ក្រុមការងារ RET | ឯ.ឧ ប៉ិច សុខា | អ្នកគ្រប់គ្រងគម្រោងRIA | ០១២ ៦៩៨ ៩៩៩<br>pechsokha566@gmail.com |

| | | | |
|---|---|---|---|
| **របស់ ECOSOCC៖** | ឯ.ឧ អេង រត្នមុនី | ប្រធាន<br>ផ្នែកបណ្តុះបណ្តាល | ០១២ ៩១២ ០០៩ |
| | ក. សៅ កន្និកា | សមាជិកក្រុម៣ | ០៨៥ ២៥៥ ២២៨ |
| **ជំនួយការ** | ក. ឡាំ វិចហួង | បុគ្គលិករដ្ឋបាល | ០៨៩ ៣៤៨ ៧៨៧ |
| **បញ្ចូលទៅក្នុង** Database | | | |